ក្រសួងរៀបចំលំនៅឋាន

# កណ្ដឹងចាប់ផ្សែងឲ្យសញ្ញាគ្រោះអគ្គិភ័យ និង សុវត្ថិភាពរបស់លោកអ្នក



លំនៅឋានរបស់លោកអ្នកត្រូវបានបំពាក់កណ្ដឹងចាប់ផ្សែងឲ្យសញ្ញាពីគ្រោះអគ្គិភ័យដោយប្រើអគ្គិសនីនិងថ្មពិល ដែលមានការទទួលស្គាល់។ កណ្ដឹងរបស់លោកអ្នកអាចដំណើរការ ដោយថ្មពិលធ្វើពីជាតិលីជ្យូមដែលអាចមានអាយុកាលរហូតដល់ ១០ឆ្នាំ ឬក៏ជាកណ្ដឹងភ្ជាប់នឹងប្រព័ន្ធអគ្គិសនីក្នុងលំនៅឋានរបស់លោកអ្នក ហើយមានថ្ម ត្រៀមដំណើរការដោយស្វ័យប្រវត្តិ។



**កណ្ដឹងចាប់ផ្សែងឲ្យសញ្ញាអគ្គិភ័យផ្ដល់សញ្ញាឲ្យអ្នកដឹង នៅពេលមានផ្សែង និងហានិភ័យនៃអគ្គិភ័យ។លោកអ្នកគួរតែធ្វើតេស្តកណ្ដឹងចាប់ផ្សែងឲ្យសញ្ញាអគ្គិភ័យរបស់លោកអ្នកជារៀងរាល់ខែ។**

**ដើម្បីធ្វើតេស្តកណ្ដឹងចាប់ផ្សែងឲ្យសញ្ញាអគ្គិភ័យរបស់លោកអ្នក**

- ចូរឆែកពិនិត្យកណ្ដឹងដោយចុចលើប៊ូតុង "TEST"។ លោកអ្នកនឹងឮសំឡេង ប៊ីបយ៉ាងខ្លាំង។ បើដៃអ្នកចុចមិនដល់ លោកអ្នកអាចប្រើអំបោសចុចវាក៏បាន។
- ចូរថែទាំកណ្ដឹងឲ្យស្អាត កុំឲ្យមានធូលី ដោយប្រើអំបោស



## ហាម

- គ្របកណ្ដឹងដោយប្រើបង់ស្អិតបិត ថ្នាំលាប ឬវត្ថុផ្សេងទៀត
- បិទមិនឲ្យដំណើរការ ឬដកកណ្ដឹងចេញ



## ដំបូន្មានសម្រាប់សុវត្ថិភាពអគ្គិភ័យ

- ហាមជក់បារីលើគ្រែ
- ហាមដើរចោលចង្ក្រានដែលកំពុងបើកប្រើចម្អិនអាហារ
- ហាមប្រើអគ្គិសនីច្រើនជ្រុលលើសពីសមត្ថភាពកម្លាំងភ្លើង
- ចូរទុកឈើគូស និងដែកកេះឲ្យឆ្ងាយពីដៃក្មេង
- បើមានអគ្គិភ័យក្នុងលំនៅឋានរបស់លោកអ្នក ចូរចាកចេញ ហើយទូរសព្ទទៅលេខ "000"

បើលោកអ្នកមិនឮសំឡេងនៅពេលធ្វើតេស្តកណ្ដឹងចាប់ផ្សែងឲ្យសញ្ញាអគ្គិភ័យរបស់លោកអ្នក ចូរទាក់ទងទៅការិយាល័យរៀបចំលំនៅឋានដែលនៅជិតលោកអ្នកឲ្យបានឆាប់បំផុតទៅតាមទូរភាព។